MARIE STOPES CAMBODIA

# អង្គការម៉ារីស្តូបអន្តរជាតិកម្ពុជា

## ការគាំទ្រដល់ជនងាយរងគ្រោះ

# ជីវប្រវត្តិ



## លោក ឈុន ផា នរិន្ទ

**នាយកផ្នែកផ្សព្វផ្សាយ និងទំនាក់ទំនង នៃអង្គការម៉ារីស្តូបអន្តរជាតិកម្ពុជា**

- បទពិសោធន៍គ្រប់គ្រងគម្រោងផ្លាស់ប្តូរឥរិយាបថ (BCC) និងផ្សព្វផ្សាយសហគមន៍តាំងពីឆ្នាំ២០០៨
- បទពិសោធន៍បំពេញតួនាទីជាប្រធានគ្រប់គ្រងគម្រោងសុខភាពមាតា ដែលទទួលការឧបត្ថម្ភថវិកាពីរដ្ឋាភិបាលអាល្លឺម៉ង់ តាមរយៈមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) នៅក្នុងប្រទេសកម្ពុជា ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក (NMCHC) និងមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព (NCHP) ក្នុងការផលិតសម្ភារៈអប់រំស្តីអំពីសុខភាពមាតា និងសុខភាពបន្តពូជ
- បទពិសោធន៍គ្រប់គ្រងគម្រោងលើកកម្ពស់ក្រមសីលធម៌សារព័ត៌មាន ដែលទទួលការឧបត្ថម្ភថវិកាពី UNDEF និងគម្រោងរបស់វិស័យឯកជនជាច្រើនទៀត
- បច្ចុប្បន្នបំពេញការងារនៅអង្គការម៉ារីស្តូប ក្រោមគម្រោង RESPOND II និង ANCP ដែលទទួលការឧបត្ថម្ភថវិកាពីរដ្ឋាភិបាលអូស្ត្រាលី ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអប់រំផ្សព្វផ្សាយផ្លាស់ប្តូរឥរិយាបថ (BCC) ទាក់ទងនឹងការមកទទួលសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ

ដោយមានវត្តមាននៅ៣៧ប្រទេសជុំវិញពិភពលោក

**MSI Reproductive Choices** ផ្តល់សេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជជូនដល់ស្ត្រីដែលធ្វើឱ្យពួកគាត់អាចជ្រើសរើសអនាគតរបស់ពួកគាត់បានដោយខ្លួនឯង

# អង្គការម៉ារីស្តូបអន្តរជាតិ កម្ពុជា

- ចាប់តាំងពីឆ្នាំ១៩៩៨មក អង្គការម៉ារីស្តូបផ្តោតលើការពង្រឹងគុណភាពសេវានៅទូទាំងប្រទេស និងជាពិសេសការផ្តល់សេវាដែលមានគុណភាពខ្ពស់ស្របតាមស្តង់ដាអន្តរជាតិដែលត្រូវបានកំណត់នៅក្នុងចក្រភពអង់គ្លេស ជាពិសេសគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលជូនដល់គ្រប់អតិថិជន
- អង្គការម៉ារីស្តូបផ្តល់គ្រប់សេវាថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ដើម្បីជួយគាំទ្រស្ត្រីគ្រប់វ័យ និងដៃគូដោយមិនមានការរើសអើង និងរក្សាការសម្ងាត់
- ដើម្បីដករបាំងផ្នែកហិរញ្ញវត្ថុចេញពីជនងាយរងគ្រោះនៅក្នុងសហគមន៍ រួមមានជនមានពិការភាព យុវវ័យ ក្រុមជនស្រឡាញ់ភេទដូចគ្នា ស្ត្រី និងកុមាររងគ្រោះដោយអំពើហិង្សា អង្គការម៉ារីស្តូបបានដាក់ចេញនូវគោលការណ៍លើកលែងថ្លៃសេវាជូនដល់ពួកគាត់

# វីដេអូស្តីអំពីការគាំទ្ររបស់អង្គការម៉ារីស្តូបអន្តរជាតិកម្ពុជាដល់ស្ត្រីមានពិការភាព



# សូមអរគុណ
# ចំពោះការទស្សនា!

MARIE STOPES INTERNATIONAL
CAMBODIA
Phnom Penh Centre, Building F,
1st Floor Sothearos Boulevard,Sankat
Tonle Bassac Khan Chamkarmorn.
Telephone: (855) 23 994 083
Email: info@mariestopes.org.kh
www.mariestopes.org.kh